**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ០១៥៥ ..... សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការកែសម្រួលវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញក្រឹត្យ-ច្បាប់ លេខ ២២ ក្រ.ច ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៨៥ ស្តីពីពន្ធប៉ាតង់
- បានឃើញព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.

ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រកាសលេខ ១៨២១ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-** **គោលបំណង**

ប្រកាសនេះមានគោលបំណងកែសម្រួលវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់លើសកម្មភាពអាជីវកម្មរបស់អ្នកជាប់ពន្ធ ដើម្បីគ្រប់គ្រងនិងប្រមូលចំណូលពន្ធឱ្យមានប្រសិទ្ធភាព។

**ប្រការ ២.-** **គោលដៅ**

ប្រកាសនេះមានគោលដៅកែសម្រួលវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ដែលមានចែងក្នុងប្រកាសលេខ ១៨២១ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-** **វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.-** **កម្មវត្ថុនៃពន្ធ**

ពន្ធប៉ាតង់គឺជាពន្ធប្រចាំឆ្នាំ ដែលត្រូវបានកំណត់លើសកម្មភាពអាជីវកម្ម ដោយផ្អែកលើប្រភេទអ្នកជាប់ពន្ធនិងកម្រិតផលរបរ។

**ប្រការ ៥.-** **បែបបទនៃការបង់ពន្ធ**

បែបបទនៃការបង់ពន្ធប៉ាតង់ត្រូវបានកំណត់ដូចខាងក្រោម÷

១- អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មច្រើន ត្រូវបង់ពន្ធប៉ាតង់ផ្សេងគ្នាទៅតាមសកម្មភាពអាជីវកម្មនីមួយៗ។

ឧទាហរណ៍÷ អ្នកជាប់ពន្ធម្នាក់ដែលមានសកម្មភាពអាជីវកម្មទីហរ័ណ-អាហរ័ណ ដឹកជញ្ជូន និង សណ្ឋាគារ ត្រូវបង់ពន្ធប៉ាតង់សម្រាប់ ៣ សកម្មភាពអាជីវកម្មផ្សេងគ្នា។

២- សកម្មភាពជាឧបសម្ព័ន្ធនានានៃសកម្មភាពអាជីវកម្មត្រូវបានចាត់ទុកថាជាសកម្មភាពអាជីវកម្មតែមួយ។

ឧទាហរណ៍÷ សណ្ឋាគារមួយដែលមានក្លឹបកំសាន្ត ភោជនីយដ្ឋាន កន្លែងម៉ាស្សា ក្លឹបហាត់ប្រាណ ឬ សកម្មភាពដទៃដែលជាឧបសម្ព័ន្ធនៃសកម្មភាពសណ្ឋាគារដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់អ្នកជាប់ពន្ធតែមួយ និងស្ថិតក្នុងទីតាំងរួមជាមួយសណ្ឋាគារ ត្រូវបង់ពន្ធប៉ាតង់តែមួយ។

៣- អ្នកជាប់ពន្ធដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយនៅក្នុង រាជធានី-ខេត្តតែមួយ ត្រូវបង់ពន្ធប៉ាតង់តែមួយ។

៤- អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មនៅក្នុងរាជធានី-ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ទៅតាម រាជធានី-ខេត្តដែលអាជីវកម្មនោះស្ថិតនៅ។

## ប្រការ ៦.- កម្រិតប្រាក់ពន្ធប៉ាតង់ត្រូវបង់

ប្រាក់ពន្ធប៉ាតង់ត្រូវបានកំណត់ដូចខាងក្រោម÷

១- អ្នកជាប់ពន្ធតូច ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៤០០ ០០០ រៀល។

២- អ្នកជាប់ពន្ធមធ្យមត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ១ ២០០ ០០០ រៀល។

៣- អ្នកជាប់ពន្ធធំដែលមានផលរបរ÷

ក- លើសពី ៤ ០០០ លានរៀល ដល់ ១០ ០០០ លានរៀល ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៣ ០០០ ០០០ រៀល

ខ- លើសពី ១០ ០០០ លានរៀល ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៥ ០០០ ០០០ រៀល។

អ្នកជាប់ពន្ធដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយដែល ស្ថិតនៅតាមរាជធានី-ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់អប្បបរមាសម្រាប់ប្រភេទអ្នកជាប់ពន្ធនីមួយៗ ទៅតាម រាជធានី-ខេត្តដែលអាជីវកម្មនោះស្ថិតនៅ។

## ប្រការ ៧.- កាលបរិច្ឆេទបង់ពន្ធ

ពន្ធប៉ាតង់ត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។ ពន្ធប៉ាតង់ត្រូវបង់នៅរដ្ឋបាលសារពើពន្ធដែលអ្នកជាប់ពន្ធមានទីកន្លែងប្រកបអាជីវកម្មពិតប្រាកដ។

អ្នកជាប់ពន្ធដែលចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល ៦ខែដើមឆ្នាំ ត្រូវបង់ប្រាក់ពន្ធប៉ាតង់ពេញ មួយឆ្នាំ ប៉ុន្តែប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល ៦ខែចុងឆ្នាំ អ្នកជាប់ពន្ធត្រូវបង់ប្រាក់ពន្ធ ប៉ាតង់ពាក់កណ្តាល។

**ប្រការ ៨.- ប័ណ្ណប៉ាតង់**

ប័ណ្ណប៉ាតង់មានតម្លៃតែចំពោះអ្នកជាប់ពន្ធដែលមានឈ្មោះក្នុងប័ណ្ណប៉ាតង់តែប៉ុណ្ណោះ។ ករណីមានការផ្លាស់ប្តូរទីកន្លែងទៅរាជធានី-ខេត្តផ្សេង ឬផ្លាស់ប្តូរមុខរបរអាជីវកម្មថ្មី ត្រូវបង់ប្រាក់ពន្ធប៉ាតង់ថ្មីម្តងទៀត។

ក្នុងការចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃក្នុងការផ្គត់ផ្គង់ទំនិញឬសេវា អ្នកជាប់ពន្ធត្រូវមានប័ណ្ណប៉ាតង់ដែលបញ្ជាក់ពីសកម្មភាពអាជីវកម្មរបស់ខ្លួនស្របតាមកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃក្នុងការផ្គត់ផ្គង់ទំនិញឬសេវាទាំងនោះ។

អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចដាក់តាំងបង្ហាញប័ណ្ណប៉ាតង់ដែលមានសុពលភាពនៅតាមទីតាំងប្រកបអាជីវកម្មរបស់ខ្លួន។

**ប្រការ ៩.- ការឈប់ ផ្អាក ឬផ្លាស់ប្តូរម្ចាស់អាជីវកម្ម**

១- សហគ្រាសដែលស្នើសុំឈប់ឬផ្អាកអាជីវកម្ម នៅក្នុងឆ្នាំជាប់ពន្ធណាមួយ ÷

- ក- តម្រូវឱ្យបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចរន្តពាក់កណ្តាល ប្រសិនបើដាក់ពាក្យសុំឈប់ឬផ្អាកអាជីវកម្មនៅក្នុងអំឡុង ៦ខែដើមឆ្នាំ នៃឆ្នាំចរន្ត។
- ខ- តម្រូវឱ្យបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចរន្តពេញមួយឆ្នាំ ប្រសិនបើដាក់ពាក្យសុំឈប់ឬផ្អាកអាជីវកម្មនៅក្នុងអំឡុង ៦ខែចុងឆ្នាំ នៃឆ្នាំចរន្ត។

ប្រាក់ពន្ធប៉ាតង់ដែលបានបង់រួចហើយមិនត្រូវបានបង្វិលសងវិញទេ។

២- ចំពោះអាជីវកម្មដែលផ្លាស់ប្តូរម្ចាស់ បើម្ចាស់ចាស់បានបង់ពន្ធប៉ាតង់ហើយ ម្ចាស់ថ្មីមិនបាច់បង់ពន្ធប៉ាតង់ជាថ្មីទៀតទេ ប្រសិនបើមានគ្រប់លក្ខណៈពីរខាងក្រោមនេះ÷

- ក- មិនផ្លាស់ប្តូរសកម្មភាពអាជីវកម្ម។
- ខ- ម្ចាស់ថ្មីជាឪពុក ម្តាយ ប្តី ប្រពន្ធ កូន ឬអ្នកស្នងស្របច្បាប់របស់ម្ចាស់អាជីវកម្មចាស់។

**ប្រការ ១០.- និរាករណ៍**

ប្រកាសលេខ ១៨២១ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ត្រូវទុកជានិរាករណ៍។

**ប្រការ ១១.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកឬអគ្គនាយក

នៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ១២កើត ខែអាសាឍ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

### ៣- ការវាយតម្លៃសាកល្បង អំពីសំវិធានធនលើអ៊ីមភែរមិន សម្រាប់ឆ្នាំ ២០១៨

ផ្អែកលើប្រកាសលេខ ធ៧-០១៧-៣៤៤ ប្រ.ក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវរៀបចំការវាយតម្លៃឲ្យបានពេញលេញអំពីតម្រូវការសំវិធានធនលើអ៊ីមភែរមិន ស្របតាមបញ្ញត្តិនានាចាប់ពីប្រការ ៤៩ ដល់ប្រការ ៧១ ដូចខាងក្រោម៖

- លើកទី ១៖ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវគណនាសំវិធានធនលើអ៊ីមភែរមិន ដោយយកទិន្នន័យគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ និងត្រូវរាយការណ៍លទ្ធផលនៃការគណនាសំវិធានធនលើអ៊ីមភែរមិន ទៅតាមការចាត់ថ្នាក់ហានិភ័យឥណទាននីមួយៗនៃហ្វាស៊ីលីធីមកធនាគារជាតិនៃកម្ពុជា ឲ្យបានមុនថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨។ ការវាយតម្លៃនេះនឹងជួយគ្រឹះស្ថានក្នុងការរៀបចំគោលនយោបាយ និងនីតិវិធីផ្ទៃក្នុងគ្រប់គ្រាន់ដើម្បីគណនាតម្រូវការសំវិធានធនលើអ៊ីមភែរមិនដោយយោងតាមវិធានថ្មីនានា។
- លើកទី ២៖ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវគណនាសំវិធានធនលើអ៊ីមភែរមិន ដោយយកទិន្នន័យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងត្រូវរាយការណ៍លទ្ធផលនៃការគណនាសំវិធានធនលើអ៊ីមភែរមិន ទៅតាមការចាត់ថ្នាក់ហានិភ័យឥណទាននីមួយៗនៃហ្វាស៊ីលីធីមកធនាគារជាតិនៃកម្ពុជា ឲ្យបានមុនថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩។

របាយការណ៍លទ្ធផលនេះ ត្រូវបង្ហាញឲ្យច្បាស់អំពីចំនួនសំវិធានធនលើអ៊ីមភែរមិនទៅតាមការចាត់ថ្នាក់ហានិភ័យឥណទាននីមួយៗ (Credit Risk Grading) នៃហ្វាស៊ីលីធី ដោយត្រូវឆ្លុះបញ្ចាំងពីតម្រូវការជាក់ស្តែងក្នុងការធ្វើសំវិធានធនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវរៀបចំការវាយតម្លៃសំវិធានធនខាងលើនេះ ដោយការយកចិត្តទុកដាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

### ៤- គោលនយោបាយនិងនីតិវិធីឥណទាន

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរៀបចំ និងផ្ញើគោលនយោបាយនិងនីតិវិធីឥណទានស្របតាមប្រកាសលេខ ធ៧-០១៧-៣៤៤ ប្រ.ក មកធនាគារជាតិនៃកម្ពុជា យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។ ក្នុងករណី មានការធ្វើបច្ចុប្បន្នកម្មលើគោលនយោបាយនិងនីតិវិធីឥណទានដែលបានរៀបចំរួចហើយ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវផ្ញើគោលនយោបាយនិងនីតិវិធីឥណទាននោះមកធនាគារជាតិនៃកម្ពុជាក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ ក្រោយពីក្រុមប្រឹក្សាភិបាលបានអនុម័ត។

ដោយផ្អែកលើរបាយការណ៍របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអំពីការធ្វើចំណាត់ថ្នាក់ និងសំវិធានធន ធនាគារជាតិនៃកម្ពុជាអាចតម្រូវឲ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់ព័ត៌មានបន្ថែម និងត្រូវកែប្រែគោលនយោបាយនិងនីតិវិធី ព្រមទាំងការអនុវត្តគោលនយោបាយនិងនីតិវិធីទាំងនោះ។

**៥- ការកត់ត្រាសំវិធានធនជាក់លាក់ និងការប្រាក់បង្គរ**

ក្នុងការអនុវត្តតម្រូវការសំវិធានធនតាមបទប្បញ្ញត្តិ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវធ្វើសំវិធានធនជាក់លាក់ (Specific provision) ឲ្យបានគ្រប់គ្រាន់ និងកត់ត្រានៅក្នុងគណនីរបស់គ្រឹះស្ថានឲ្យបានត្រឹមត្រូវតាមស្ថានភាពជាក់ស្តែងរបស់សមភាគី ហើយទទួលស្គាល់ជាចំណាយនៅក្នុងរបាយការណ៍ចំណេញ-ខាតតាមគ្រា មកធនាគារជាតិនៃកម្ពុជា។ នៅពេលណាដែលសមតុល្យគណនីរបស់អតិថិជនមានបញ្ចូលមូលធនកម្មការប្រាក់ ដែលបានកត់ត្រាបដិភាគជាមួយការប្រាក់ព្យួរទុក មូលធនកម្មការប្រាក់នេះមិនត្រូវយកមកគិតសម្រាប់គណនាសំវិធានធនទេ។

ផ្អែកលើគោលការណ៍គណនេយ្យបង្គរ (Accrual Accounting Principle) ការប្រាក់បង្គរលើហ្សាស៊ីលីធីដំណើរការ ត្រូវកត់ត្រាជាចំណូលក្នុងគណនីចំណេញ-ខាត ចំណែកការប្រាក់បង្គរលើហ្សាស៊ីលីធីទាំងឡាយណាដែលត្រូវបានចាត់ថ្នាក់ជាហ្សាស៊ីលីធីក្រោមស្តង់ដារ ហ្សាស៊ីលីធីសង្ស័យ ឬហ្សាស៊ីលីធីបាត់បង់ ត្រូវកត់ត្រាក្នុងខ្ទង់ទ្រព្យអកម្មនៃតារាងតុល្យការក្នុងគណនីការប្រាក់ព្យួរទុក។

**៦- ការអនុវត្តប្លង់គណនី**

ដើម្បីសម្រួលដល់ការចុះកិច្ចបញ្ជិកាគណនេយ្យ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើត្រូវអនុវត្តប្លង់គណនីឯកភាព (Uniform Chart of Accounts) ដូចគ្រឹះស្ថានធនាគារ។ ចំណែកឯ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវអនុវត្តប្លង់គណនីឯកភាពដែលកំពុងប្រើប្រាស់បច្ចុប្បន្ន។

**៧- ចំណាត់ថ្នាក់ និងសំវិធានធនតាមបទប្បញ្ញត្តិសម្រាប់ហ្សាស៊ីលីធីរយៈពេលខ្លី**

ចំណាត់ថ្នាក់និងសំវិធានធនសម្រាប់ហ្សាស៊ីលីធីរយៈពេលខ្លីត្រូវបានកំណត់ដូចខាងក្រោម៖

| ប្រភេទហ្សាស៊ីលីធី (រយៈពេលខ្លី) | ចំនួនថ្ងៃហួសកាលកំណត់សង | សំវិធានធនតាមបទប្បញ្ញត្តិ |
|---|---|---|
| ធម្មតា | តិចជាង ឬស្មើ ១៤ ថ្ងៃ | ១% |
| ឃ្លាំមើល | ១៥ ដល់ ៣០ ថ្ងៃ | ៣% |
| ក្រោមស្តង់ដារ | ៣១ ដល់ ៦០ ថ្ងៃ | ២០% |
| សង្ស័យ | ៦១ ដល់ ៩០ ថ្ងៃ | ៥០% |
| បាត់បង់ | ចាប់ពី ៩១ ថ្ងៃ ឡើងទៅ | ១០០% |

**៨- ការធ្វើសំវិធានធនសម្រាប់ខ្ទង់ក្រៅតារាងតុល្យការ**

**ក. ឥណទានវិបារូបន៍**

ទំហំសំវិធានធនចំពោះឥណទានវិបារូបន៍នឹងត្រូវគណនាដោយផ្អែកលើ សមតុល្យនៃឥណទានវិបារូបន៍ដែលបានប្រើប្រាស់ ឬកម្រិតអនុម័តឥណទានវិបារូបន៍ ឬសមតុល្យដែលបានប្រើប្រាស់លើស



ႊ

កម្រិតអនុម័ត អាស្រ័យលើគោលនយោបាយឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនីមួយៗ។ ឧទាហរណ៍ ក្នុងករណីគោលនយោបាយ ឬកិច្ចសន្យារបស់គ្រឹះស្ថានចែងថា នៅពេលឥណទានវិបារូបន៍ត្រូវបានចាត់ថ្នាក់ចាប់ពីចំណាត់ថ្នាក់ឃ្លាំមើល ជាស្វ័យប្រវត្តិ អ្នកខ្ចីគ្មានសិទ្ធិ ឬមិនអាចដកយកចំណែកឥណទានដែលនៅសល់ទៅប្រើប្រាស់បាន នោះការធ្វើសំវិធានធនត្រូវផ្អែកលើសមតុល្យនៃឥណទានវិបារូបន៍ដែលបានប្រើប្រាស់។ ផ្ទុយទៅវិញ ក្នុងករណីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុគ្មានគោលនយោបាយដែលហាមឃាត់អតិថិជនដកឥណទានវិបារូបន៍យកទៅប្រើប្រាស់ដូចខាងលើទេ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវធ្វើសំវិធានធនដោយផ្អែកលើកម្រិតអនុម័តឥណទានវិបារូបន៍ ឬសមតុល្យដែលបានប្រើប្រាស់លើសកម្រិតអនុម័ត។

**ខ. ខ្ទង់ផ្សេងៗទៀតនៃក្រៅតារាងតុល្យការ**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវធ្វើសំវិធានធនលើកម្រិតអនុម័តនៃកិច្ចសន្យាឥណទាន ឬកិច្ចសន្យាផ្សេងទៀតដែលបានចុះកិច្ចសន្យារួចហើយ ដែលគ្រឹះស្ថានមិនអាចបដិសេធបាន ដោយសារតែកិច្ចសន្យាទាំងនេះនឹងអាចក្លាយទៅជាកាតព្វកិច្ចទូទាត់របស់គ្រឹះស្ថាន។

ចំពោះផលិតផលហិរញ្ញប្បទានពាណិជ្ជកម្ម ដូចជាលិខិតឥណទាន ឬការធានាឥណទានដែលធានាដោយប្រាក់បញ្ញើ (Margin Deposit) សំវិធានធនត្រូវគណនាដោយផ្អែកលើកម្រិតអនុម័តដកចេញប្រាក់បញ្ញើធានាដែលមានឥណប្រតិទានលើសពីឥណប្រតិទានរបស់ផលិតផលនោះ។

សារាចរណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសាភិបាល**

ជា-ចាន់តូ

**កន្លែងទទួល៖**
- អគ្គលេខាធិការដ្ឋាន
- អគ្គនាយកដ្ឋានត្រួតពិនិត្យ
- អគ្គនាយកដ្ឋានបច្ចេកទេស
- អគ្គបេឡា
- អគ្គាធិការដ្ឋាន
- គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្តីការគណៈរដ្ឋមន្ត្រី